# ប្រវត្តិនិងវិវត្តន៍នៃក្រុមប្រឹក្សាធម្មនុញ្ញ

*ដោយ* : **បណ្ឌិត ហែម ឡាច**
*ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នកំពូលមួយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣។ ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់ហើយ។*

*ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។*

## ១. ប្រវត្តិក្រុមប្រឹក្សាធម្មនុញ្ញ

*នៅក្នុងប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាពុំដែលមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទេ។ រដ្ឋធម្មនុញ្ញទី១នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧ ហើយដែលបានកែប្រែជាបន្តបន្ទាប់រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៦៤ ក៏បាននិយាយនៅក្នុងមាត្រា១១៩ តែពីសិទ្ធិបកស្រាយអត្ថបទធម្មនុញ្ញ ហើយមិនមាននិយាយពីការត្រួតពិនិត្យធម្មនុញ្ញភាពទេ។ សិទ្ធិបកស្រាយចុងក្រោយជារបស់រដ្ឋសភា។*

*រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ បានបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពមួយដែលដាក់ឈ្មោះថា "តុលាការធម្មនុញ្ញ"។ ទោះបីជាមានឈ្មោះជាតុលាការធម្មនុញ្ញយ៉ាងណាក៏ដោយ ក៏អង្គការនេះស្ថិតដោយឡែកពីអង្គការតុលាការដែរ។ តុលាការធម្មនុញ្ញនេះមានសមាជិក៦រូប និងមានអាណត្តិ៦ឆ្នាំ ប៉ុន្តែចំនួនពាក់កណ្តាលនៃសមាជិក ត្រូវបញ្ចប់អាណត្តិក្នុងរយៈពេល៣ឆ្នាំម្តង។ បេក្ខជនត្រូវជ្រើសរើសចេញពីបញ្ញវន្ត ឬអ្នកមានបទពិសោធន៍ច្រើនឆ្នាំហើយជាអាទិភាពចំពោះអ្នកដែលមិនចូលក្នុងគណបក្សណាមួយ។ វិធីនៃការជ្រើសរើសគឺៈ ២រូបជ្រើសរើសដោយប្រធានាធិបតី ដែលសម្រេចដោយគណៈរដ្ឋមន្ត្រី ២រូបជ្រើសរើសដោយរដ្ឋសភា និង២រូបជ្រើសរើសដោយព្រឹទ្ធសភាក្រៅពីសមាជិករបស់ខ្លួន។ តុលាការនេះជ្រើសរើសសមាជិកម្នាក់ជាប្រធាន ដែលមានសំឡេង ឧត្តមានុ*

ភាពក្នុងករណីអនុម័តមានសំឡេងស្មើគ្នា។ សមាជិកតុលាការធម្មនុញ្ញ មានវិសមិតភាពទៅនឹងមុខងារប្រធានាធិបតី អនុប្រធានាធិបតី សមាជិករដ្ឋាភិបាល សមាជិកសហសភា សមាជិកតុលាការជាន់ខ្ពស់ និងសមាជិកតុលាការកំពូល។ តួនាទីតុលាការធម្មនុញ្ញមានដូចជា៖ ដោះស្រាយវិវាទដែលទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតី ដោះស្រាយវិវាទដែលទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកសហសភា បកស្រាយចុងក្រោយនូវបទបញ្ញត្តិរដ្ឋធម្មនុញ្ញនិងពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ដែលមាន១៦ជំពូកនិង២១មាត្រាក៏មិនឃើញមានចែងអំពីស្ថាប័នដែលមានសិទ្ធិបកស្រាយអត្ថបទធម្មនុញ្ញដែរ។

រដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១ អនុញ្ញាតឱ្យមានការបកស្រាយច្បាប់ដោយក្រុមប្រឹក្សារដ្ឋ ក្នុងឋានៈជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា។ ចាប់តាំងពីឆ្នាំ១៩៨៩ ដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាបានចែងអំពីការបកស្រាយច្បាប់ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។ ប៉ុន្តែនៅពេលនោះ ការបកស្រាយធម្មនុញ្ញ និងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ពុំទាន់មានឡើយ។

បន្ទាប់ពីមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី១ ដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជាដែលហៅកាត់ថាអ៊ុនតាក់ (UNTAC) ថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញមួយត្រូវបានបង្កើតឡើង។ សភាធម្មនុញ្ញថ្មីនេះ មានភារកិច្ចតាក់តែងរដ្ឋធម្មនុញ្ញថ្មីមួយ។ រដ្ឋធម្មនុញ្ញថ្មីដែលបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញ ត្រូវបានប្រកាសប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ជំពូកទី១២ ថ្មី នៃរដ្ឋធម្មនុញ្ញមានចែងអំពីក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញបានចាប់ផ្តើមដំណើរការពេញលក្ខណៈនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨។

សូមជម្រាបថា គិតមកដល់ឆ្នាំ២០២៥ នេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានធ្វើវិសោធនកម្មចំនួន១១ លើកគឺ៖

-**លើកទី១៖** ប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤

-**លើកទី២៖** ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៣៩៩/ ០១ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៤។

-**លើកទី៣៖** ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៧០១/ ១១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០១។

***-លើកទី៤៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ០៦០៥/ ០១៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។*

***-លើកទី៥៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ០៣០៦/ ០០៦ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦។*

***-លើកទី៦៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ០២០៨/ ០០៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។*

***-លើកទី៧៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ១០១៤/ ០២២ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤។*

***-លើកទី៨៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ០២១៨/ ០០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨។*

***-លើកទី៩៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ១១២១/ ០១៦ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១។*

***-លើកទី១០៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ០៨២២/ ០០៧ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២។*

***-លើកទី១១៖*** *ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/ រកម/ ០៩២៥/ ០៣០ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥។ ច្បាប់ធម្មនុញ្ញបន្ថែមសំដៅជានាទូរដំណើរការជាប្រក្រតីនៃស្ថាប័នជាតិដែលមាន៧មាត្រា ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៧០៤/ ០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤។*

## ២. សមាសភាពក្រុមប្រឹក្សាធម្មនុញ្ញ

*ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។*

*-សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ*

*-សមាជិកបីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា*

*-សមាជិកបីរូបត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។*

*សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ រៀងរាល់៣ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល បន្ទាប់ពីសមាជិកថ្មី៣រូបចូលកាន់តំណែង។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវបានជ្រើសតាំងជាថ្មីបាន។ ប្រធានមានសំឡេងឧត្តមានុភាព ក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈនិងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈនិងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។*

## ៣. លក្ខណសម្បត្តិ

*សមាជិកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសរើសក្នុងចំណោមឥស្សរជនដែល៖*

*-មានសញ្ជាតិខ្មែរពីកំណើត*

*-មានអាយុយ៉ាងតិច៤៥ឆ្នាំ*

-មានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ឆ្នាំ

-មានសញ្ញាប្រតចាប់ពីឧត្តមសិក្សាឡើងទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច។

ក្នុងរយៈពេល៣ឆ្នាំម្តង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ត្រូវផ្លាស់ប្តូរនិងតែងតាំងជាថ្មី គឺតែងតាំងដោយព្រះមហាក្សត្រ១រូប តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម១រូប និងជ្រើសតាំងដោយរដ្ឋសភា១រូប។ នៅអាណត្តិទី១ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវមានសមាជិក៣រូប តែងតាំងនិងជ្រើសតាំងសម្រាប់រយៈពេល៣ឆ្នាំ ៣រូប តែងតាំងនិងជ្រើសតាំងសម្រាប់រយៈពេល៦ឆ្នាំ និង៣រូបតែងតាំងនិងជ្រើសតាំងសម្រាប់រយៈពេល៩ឆ្នាំ។ សមាជិកមកជំនួសថ្មី ដែលអាណត្តិមានរយៈពេលតិចជាងឬស្មើនឹង៣ឆ្នាំអាចត្រូវតែងតាំងឬជ្រើសតាំងសម្រាប់មួយអាណត្តិទៀតបាន។

## ៤. វិសមិតភាពនិងអភ័យឯកសិទ្ធិ

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារៈ

-សមាជិកព្រឹទ្ធសភា

-សមាជិករដ្ឋសភា

-សមាជិករាជរដ្ឋាភិបាល

-ចៅក្រមក្នុងតំណែង

-ការកាន់តំណែងណាមួយក្នុមុខងារសាធារណៈ

-ប្រធាន ឬអនុប្រធានគណបក្សនយោបាយ

-ប្រធាន ឬអនុប្រធានសហជីព

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើឡើងនៅពេលបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ។ ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយពីតំណែង តម្រូវឱ្យមានការយល់ព្រមពីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនពីរភាគបីនៃចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល នៅក្នុងសវនាការមិនសាធារណៈ និងដោយមានវត្តមានរបស់សាមីខ្លួន។ ក្រុមប្រឹក្សាធម្មនុញ្ញអាចដកចេញពីតំណែងនូវសមាជិកណា ដែលមានវិសមិតភាពមុខតំណែង ឬដែលមិនបានមកប្រជុំលើសពី៣ដងផ្ទួនៗគ្នា ដោយឥតជូនដំណឹងជាមុន ឬដែលមិនអាចបំពេញមុខងារជាប្រៀងរហូតបាន ដោយបាត់បង់សមត្ថភាពខាងបញ្ញា ឬរូបកាយជាអចិន្ត្រៃយ៍។

## ៥. តួនាទីសំខាន់ៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

-ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយ

ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។

-ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

-ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

-ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ។

-ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។

-ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។

-ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាល របស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ។

## ៦. ក្រុមប្រឹក្សាធម្មនុញ្ញនិងស្ថាប័នផ្សេងៗ

### ៦.១. ព្រះមហាក្សត្រនិងក្រុមប្រឹក្សាធម្មនុញ្ញ

ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្ដីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។ ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភាតាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។

### ៦.២. ក្រុមប្រឹក្សាធម្មនុញ្ញនិងប្រជារាស្ត្រ

ប្រជារាស្ត្រអាចលើកឡើងប្ដឹងទៅតុលាការអំពីបញ្ហាអធម្មនុញ្ញភាពនៃច្បាប់ ឬសេចក្ដីសម្រេចរបស់ស្ថាប័ននានារបស់រដ្ឋ ដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជា សារវន្តរបស់គេតាមរយៈរឿងក្ដីរបស់ខ្លួននៅតុលាការ។ តុលាការថ្នាក់ក្រោម

បញ្ជូនពាក្យបណ្តឹងខាងលើនេះទៅតុលាការកំពូល។ តុលាការកំពូលជាអ្នកបញ្ជូនបណ្តឹងនោះបន្តមកក្រុមប្រឹក្សាធម្មនុញ្ញ បើសិនជាតុលាការកំពូលយល់ឃើញថាសមហេតុសមផល។

បញ្ហាដែលកើតឡើងនោះ ជាបញ្ហាបន្ទាន់បង្ខំដល់តុលាការទទួលបន្ទុកជំនុំជម្រះត្រូវផ្អាកសិន ដោយរង់ចាំចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាមុន។ ក្នុងករណី គ្មានរឿងក្តីក៏ដោយប្រជាពលរដ្ឋមាន សិទ្ធិប្តឹងសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ណា ដែលប្រកាសឱ្យប្រើហើយ។ ប្រជាពលរដ្ឋត្រូវប្តឹងតាមរយៈ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬតំណាងរាស្ត្រចំនួនមួយភាគដប់។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិ ពិនិត្យ និងសម្រេចជូនប្រជាពលរដ្ឋអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាក្នុងករណីដែល ប្រជាពលរដ្ឋមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ. ជ. ប.)។

## ៦.៣. ក្រុមប្រឹក្សាធម្មនុញ្ញនិងគណបក្សនយោបាយ

ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ និងសម្រេចជូនគណបក្សនយោបាយតាមបណ្តឹងផ្ទាល់ (បណ្តឹងនេះធ្វើបានតែក្នុងរយៈពេល ៧២ម៉ោង យ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន) ឬតាមបណ្តឹងឧទ្ធរណ៍ មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្នុងការដោះស្រាយវិវាទកម្មទាក់ទង នឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការដោះស្រាយបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នឹងបញ្ជីដំបូងនៃការចុះឈ្មោះបោះឆ្នោត និងការដោះស្រាយបណ្តឹងក្នុងពេលឃោសនាបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញបំពេញតួនាទីដូចតុលាការ។

## ៦.៤. ក្រុមប្រឹក្សាធម្មនុញ្ញនិងអធិបតេយ្យជាតិ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនៃការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើគ្រប់អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ក្នុងក្របខ័ណ្ឌនៃការត្រួត

ពិនិត្យធម្មនុញ្ញភាពតាមសំណើពីព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬតុលាការ។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចពិនិត្យជាអាទិកាល ឬបច្ឆាកាល នូវធម្មនុញ្ញភាពនៃច្បាប់ក្នុងលក្ខខណ្ឌខាងលើនេះលើកលែងតែច្បាប់រៀបចំអង្គការបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្មច្បាប់រៀបចំអង្គការបទបញ្ជាផ្ទៃក្នុងទាំងនោះ ដែលត្រូវតែពិនិត្យមុននឹងប្រកាសឱ្យប្រើ ឬមុននឹងដាក់ឱ្យអនុវត្តន៍។

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ មានតែព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន និងតំណាងរាស្ត្រមួយភាគដប់ ឬតុលាការប៉ុណ្ណោះដែលអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន។

ប្រជារាស្ត្រ និងគណបក្សនយោបាយ អាចលើកសំណ ឬប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមលក្ខខណ្ឌដែលមានចែងខាងក្រោយ។

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

(១៩៩៨-បច្ចុប្បន្ន)៖

១-ឯកឧត្តម **ចាន់ សុក** ១អាណត្តិ (១៩៩៨-២០០១)

២-ឯកឧត្តម **ប៊ិន ឈិន** ២អាណត្តិ (២០០១-២០០៧)

៣-ឯកឧត្តម **ឯក សំអុល** ៣អាណត្តិ (២០០៧-២០១៦)

៤-ឯកឧត្តម **កិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម** ៣អាណត្តិ (២០១៦-២០២៥)

៥-ឯកឧត្តម **ហ៊ី សោភា** (២០២៥-បច្ចុប្បន្ន)




(**រូបថត** : Lor Krem)

**ឯកសារពិគ្រោះ**

*១-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៧*

*២-សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២*

*៣-ហ្គូត វុទ្ធី៖ ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៧-២០០៧*

*៤-ហែម ឡាច៖ ស្ថាប័ននយោបាយកម្ពុជាបច្ចុប្បន្ន ឆ្នាំ២០២៣*

*៥-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣*

៦-http://www.ccc.gov.kh (http://ccc.gov.kh/)

*៧ -https://plus.freshnewsasia.com/knowledge/402717-2025-09-24-19-59-36*